ដោះស្រាយវិវាទការងាររួម

# ព្រឹត្តិបត្រក្រុមប្រឹក្សាអាជ្ញាកណ្តាល

ព័ត៌មានថ្មីៗអំពីទំនាក់ទំនងវិជ្ជាជីវៈ និងការដោះស្រាយវិវាទការងារនៅកម្ពុជា

ខែតុលា-ធ្នូ ឆ្នាំ២០១៤

## មាតិកា


| | |
|---|---|
| ការដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលពីខែតុលា ដល់ ខែធ្នូ ឆ្នាំ២០១៤ | ១ |
| ទីភ្នាក់ងារសហប្រតិបត្តិការ និងអភិវឌ្ឍន៍ប្រទេសស្វីស ផ្តល់ជំនួយដល់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល | ២ |
| ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការផ្តល់ជំនួយដល់ការងារដោះស្រាយវិវាទការងារ | ៣ |
| ដំណើរទស្សនកិច្ចនៅគណៈកម្មាធិការការងារយុត្តិធម៌ប្រទេសអូស្ត្រាលី | ៤ |
| មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបើកវគ្គបណ្តុះបណ្តាលកម្មករនិយោជិត និងតំណាងនិយោជក | ៤ |
| សិទ្ធិចាត់ចែង-គ្រប់គ្រងនឹងសុខភាព-សុវត្ថិភាពរបស់កម្មករនិយោជិត | ៥ |
| អាជ្ញាកណ្តាល សុខ ម៉ាធឿង៖ ខ្ញុំចង់ឃើញកម្ពុជាដូចប្រទេសជឿនលឿនដទៃ | ៦ |
| ទំព័របុគ្គលិក | ៨ |


## ការដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល

ហ៊ុន ចិន្តា និងស្រី សុមេធ

### ការចុះបញ្ជី និងដោះស្រាយសំណុំរឿង ៖ ត្រីមាសចុងក្រោយឆ្នាំ ២០១៤




ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចុះបញ្ជីសំណុំរឿងចំនួន ៨៦ ពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០១៤ ចំនួនសំណុំរឿងនេះមានកំណើនរហូតដល់ ៣០% ធៀបនឹងត្រីមាសដូចគ្នាក្នុងឆ្នាំ២០១៣ ដែលមានត្រឹមតែ ៦៦ សំណុំរឿង។ ការកើនឡើងយ៉ាងគំហុកនៃចំនួនសំណុំរឿងនេះ បញ្ជាក់ថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលកាន់តែមានភាពសកម្មថែមទៀតក្នុងការផ្តល់សេវាដោះស្រាយវិវាទការងារ។ គិតជាមធ្យម ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលសំណុំរឿងចំនួន ២៦ ក្នុងមួយខែ ក្នុងនោះ ខែតុលា មាន ៣៤ សំណុំរឿង ខែវិច្ឆិកា និងធ្នូ មាន ២៦ សំណុំរឿងដូចគ្នា។

ទោះបីជាសំណុំរឿងភាគច្រើនមានប្រភពមកពីវិស័យកាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើងក្តី ក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្តល់សេវាដោះស្រាយវិវាទការងារដល់គ្រប់វិស័យ និងកម្មករនិយោជិតគ្រប់ប្រភេទ។ វិស័យកាត់ដេរសំលៀកបំពាក់នៅតែជាប្រភពនៃសំណុំរឿងច្រើនជាងគេ ដែលមានរហូតដល់ ៨៣% (៧១/៨៦) នៃចំនួនសំណុំរឿង

តទៅទំព័រ ២




ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបោះផ្សាយរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួននៅដើម ខែមីនា ឆ្នាំ២០១៥

►

◄

លោកអ្នកអាចរកកម្រងឯកសារច្បាប់ស្តីពីការងារ (ជាភាសាខ្មែរ) នៅការិយាល័យក្រុមប្រឹក្សាអាជ្ញាកណ្តាល



## ការចុះបញ្ជី...

តមកពីទំព័រ ១

សរុបក្នុងត្រីមាសនេះ។ ប៉ុន្តែសំណុំរឿងមកពីវិស័យផ្សេងទៀតក៏មានការកើនឡើងដែរ អត្រាចំនួនសំណុំរឿងមកពីវិស័យទាំងនោះកើនឡើងដល់ ១៧% (២៥/៨៦) នៃចំនួនសំណុំរឿងទាំងអស់ក្នុងនោះមាន៖ វិស័យផលិតកម្ម (៨%), វិស័យបដិសណ្ឋារកិច្ច និងទេសចរណ៍ (២%), វិស័យសេវាកម្ម (៣%), វិស័យផ្គត់ផ្គង់ឱសថ និងសុខាភិបាល (៣%), និងវិស័យផ្សេងៗទៀត។

ក្រាហ្វនៅខាងស្តាំនេះបង្ហាញអំពីប្រភពនៃសំណុំរឿងចេញពីវិស័យនានា។




### ការដោះស្រាយសំណុំរឿង

ក្នុងចំណោមសំណុំរឿងចំនួន ៨៦ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចសេចក្តីតាមរយៈការចេញសេចក្តីបង្គាប់ចំនួន ៣២ សំណុំរឿង។ រីឯសំណុំរឿងចំនួន ២១ ទៀតត្រូវបានដោះស្រាយតាមរយៈកិច្ចព្រមព្រៀងរវាងភាគីវិវាទ និងការដកពាក្យបណ្តឹងរបស់ភាគីវិវាទ។ ចំណែកសំណុំរឿងចំនួន ១១ ផ្សេងទៀត ត្រូវក្រុមប្រឹក្សាអាជ្ញាកណ្តាលបិទ ក្នុងនោះសំណុំរឿងចំនួន ១១ ត្រូវបានបិទដោយសារកូដកម្ម ហើយសំណុំរឿង ៣ ទៀត ត្រូវបានបិទដោយសារភាគីអវត្តមានក្នុងសវនាការ។ សំណុំរឿងចំនួន ១៩ កំពុងស្ថិតក្នុងដំណើរការនៅឡើយ ហើយនឹងរង់ចាំការដោះស្រាយក្នុងត្រីមាសទីមួយនៃឆ្នាំ ២០១៥។

ក្រាហ្វនេះបង្ហាញអំពីការដោះស្រាយសំណុំរឿង។




## ទីភ្នាក់ងារសហប្រតិបត្តិការ និងអភិវឌ្ឍន៍ប្រទេសស្វីសផ្តល់ជំនួយដល់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល

ស្រី សុមេធ

ទីភ្នាក់ងារសហប្រតិបត្តិការ និងអភិវឌ្ឍន៍ប្រទេសស្វីសបានផ្តល់ប្រាក់ជំនួយដល់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលចំនួន ៤៩.០០០ដុល្លារសហរដ្ឋអាមេរិកតាមរយៈគម្រោង "ការលើកតម្កើងការងារ និងទំនាក់ទំនងការងារល្អ" ដោយចាប់ផ្តើមពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥។

លោកស្រី រ៉ាហែល បសង់ នាយកផ្នែកសហប្រតិបត្តិការនៃការិយាល័យសហប្រតិបត្តិការប្រទេសស្វីស និង លោក ម៉ែន និម្មិត នាយកប្រតិបត្តិស្តីទីមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះនៅខែវិច្ឆិកា ឆ្នាំ២០១៤។



លោក ម៉ែន និម្មិត និងលោកស្រី រ៉ាហែល បសង់ ចុះហត្ថលេខាលើកិច្ចព្រមព្រៀង

# ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការផ្តល់ជំនួយដល់ការងារដោះស្រាយវិវាទការងារ

ស្រី សុមេធ

មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបាន រៀបចំពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពី ការផ្តល់ជំនួយដល់មូលនិធិនេះ។ កិច្ចព្រមព្រៀង ដែលចុះហត្ថលេខាដោយមូលនិធិក្រុមប្រឹក្សា អាជ្ញាកណ្តាល និងស្ថានទូតស៊ុយអែតប្រចាំនៅ ប្រទេសកម្ពុជាកាលពីថ្ងៃសុក្រ ទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅឯសណ្ឋាគារអាំងទែរកុងទីណង់តាល់ ជាការចាប់ផ្តើមនៃទំនាក់ទំនងផ្តល់ជំនួយជាទឹក ប្រាក់ ១,២ លានដុល្លារសហរដ្ឋអាមេរិក សម្រាប់ រយៈពេល ២ឆ្នាំ។ ពិធីនេះមានការចូលរួមពី សំណាក់មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលកម្ពុជា មន្ត្រី ស្ថានទូតស៊ុយអែត ថ្នាក់ដឹកនាំសហភាពសហព័ន្ធ សហជីព តំណាងនិយោជក ម្ចាស់ជំនួយ និង ភាគីពាក់ព័ន្ធជាច្រើន។




លោក ម៉ែន និម្មិត និងលោកជំទាវ អាណាណា ម៉ាយ ហ៊ុលធ៍ហ្គាដ ចាប់ដៃ បន្ទាប់ពីចុះហត្ថលេខាលើកិច្ចព្រមព្រៀង

លោក ម៉ែន និម្មិត នាយកប្រតិបត្តិស្តីទីនៃ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានមាន ប្រសាសន៍បើកកម្មវិធីថា ក្រោមគម្រោងនេះ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល និងរាជរដ្ឋា ភិបាលស៊ុយអែតសង្ឃឹមថានឹងអាចដោះស្រាយ បញ្ហាមួយចំនួនតាមរយៈក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលប្រើប្រាស់ជំនាញរបស់ខ្លួនដោយឯករាជ្យ និងឥតលម្អៀង។

លោកក៏បានថ្លែងអំណរគុណដល់រាជរដ្ឋា ភិបាល ស៊ុយអែត ធនាគារពិភពលោក និងនាយក ដ្ឋានកិច្ចការពាណិជ្ជកម្មអន្តរជាតិរបស់ប្រទេស អូស្ត្រាលី ចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ក្រុម ប្រឹក្សាអាជ្ញាកណ្តាល។

លោកជំទាវ អាណាណា ម៉ាយ ហ៊ុលធ៍ហ្គាដ ឯកអគ្គរាជទូតស៊ុយអែតប្រចាំនៅកម្ពុជា បាន មានប្រសាសន៍ថា ការឧបត្ថម្ភគាំទ្ររបស់ប្រទេស ស៊ុយអែតនឹងជួយកសាងបន្ថែមលើជោគជ័យ ដែលមូលនិធិ និងក្រុមប្រឹក្សាអាជ្ញាកណ្តាលមាន រួចមកហើយ។

លោកជំទាវ បានបន្ថែមថា "ខ្ញុំជឿជាក់ថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលជាស្ថាប័នមួយដ៏សំខាន់ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយ និរន្តរភាពនៅកម្ពុជា ហើយស្ថាប័ននេះអាចដើរតួ ជាគំរូមួយសម្រាប់កិច្ចសន្ទនាប្រកបដោយប្រសិទ្ធ ភាពរវាងតួអង្គទាំងឡាយក្នុងវិស័យផ្សេងៗទៀត។"

លោកជំទាវ មានប្រសាសន៍ថា "ប្រទេស ស៊ុយអែតមានមោទនភាពដែលបានចុះកិច្ច

> "ក្រុមប្រឹក្សាអាជ្ញាកណ្តាលជាស្ថាប័នមួយដ៏សំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយនិរន្តរភាពនៅកម្ពុជា ហើយស្ថាប័ននេះអាចដើរតួជាគំរូមួយ សម្រាប់កិច្ចសន្ទនាប្រកបដោយប្រសិទ្ធភាពរវាងតួអង្គទាំងឡាយក្នុងវិស័យ ផ្សេងៗទៀត។"
>
> លោកជំទាវ អាណាណា ម៉ាយហ៊ុលធ៍ហ្គាដ
> ឯកអគ្គរាជទូតស៊ុយអែតប្រចាំនៅកម្ពុជា



ព្រមព្រៀងមានរយៈពេល ២ឆ្នាំ ដោយមាន ថវិកា ១,២ លាន ដុល្លារសហរដ្ឋអាមេរិកជាមួយ នឹងមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល"។

ឯកឧត្តម អ៊ុំ មាន រដ្ឋលេខាធិការក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានមាន ប្រសាសន៍ក្នុងកម្មវិធីនេះដែរថា ការគាំទ្ររបស់ រាជរដ្ឋាភិបាលស៊ុយអែតដល់ក្រុមប្រឹក្សាអាជ្ញា កណ្តាលមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដល់ ឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ប៉ុណ្ណោះទេ វិស័យដទៃទៀតដែលប្រើប្រាស់សេវារបស់ក្រុម ប្រឹក្សាអាជ្ញាកណ្តាលក៏នឹងទទួលបានអត្ថប្រយោជន៍ ដោយផ្ទាល់ពីការគាំទ្រនេះដែរ។

សូមជម្រាបជូនផងដែរថា ក្នុងកិច្ចព្រមព្រៀង នេះ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងប្រើ ប្រាស់ជំនួយដើម្បី៖

១. ផ្តល់សេវាដោះស្រាយវិវាទការងារប្រកប ដោយប្រសិទ្ធភាពមួយដែលទាំងកម្មករនិយោជិត និង និយោជកមានការជឿជាក់។

២. លើកកម្ពស់ការយល់ដឹងអំពីក្រុមប្រឹក្សា អាជ្ញាកណ្តាល និងបង្កើនជំនាញដោះស្រាយ វិវាទការងារដល់កម្មករនិយោជិត និងនិយោជក តាមរយៈការកសាងសមត្ថភាព ភាពជាដៃគូ និង សកម្មភាពផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ។

៣. រក្សា និងលើកតម្កើងសុចរិតភាព និង និរន្តរភាពរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

# ដំណើរទស្សនកិច្ចនៅគណៈកម្មាធិការការងារយុត្តិធម៌ប្រទេសអូស្ត្រាលី

ជុំ ចរិយា

នៅក្នុងសប្តាហ៍ទី៤ នៃខែវិច្ឆិកា ឆ្នាំ២០១៤ គណៈប្រតិភូដែលមានឯកឧត្តម បណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានខុទ្ទកាល័យរបស់លោក អគ្គនាយក និង អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ លោក ម៉ែន និម្មិត នាយកប្រតិបត្តិស្តីទីមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល(ACF)អាជ្ញាកណ្តាល ម៉ារ សំបូណា និងលោកស្រី ជុំ ចរិយា ប្រធានផ្នែកសេវាច្បាប់ (ACF) បានបំពេញទស្សនកិច្ច នៅគណៈកម្មាធិការការងារយុត្តិធម៌ក្នុងទីក្រុង ម៉េលបឺន ប្រទេសអូស្ត្រាលី។ ក្នុងដំណើរទស្សនកិច្ចរយៈពេលពីរបីថ្ងៃនេះ គណៈប្រតិភូ បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ជាមួយនឹងអាជ្ញាកណ្តាល រដ្ឋបាល និងលេខាធិការនៃគណៈកម្មាធិការនេះ។



គណៈប្រតិភូកម្ពុជាស្តាប់បទបង្ហាញអំពីការងាររបស់គណៈកម្មាធិការការងារយុត្តិធម៌អូស្ត្រាលី ក្នុងដំណើរទស្សនកិច្ចនោះ។

គណៈប្រតិភូក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានសម្តែងចំណាប់អារម្មណ៍ខ្ពស់ចំពោះបទបង្ហាញដែលធ្វើឡើងដោយគណៈកម្មការការងារយុត្តិធម៌អូស្ត្រាលី ជាពិសេស គឺបទបង្ហាញស្តីពីការកំណត់ប្រាក់ឈ្នួលគោល តាមរយៈសវនាការ និងចេញសេចក្តីបង្គាប់។ ក្នុងការជួយដល់ការងារដ៏មានសារៈសំខាន់នៃការកំណត់ប្រាក់ឈ្នួលគោលថ្នាក់ជាតិរបស់គណៈកម្មាធិការការងារយុត្តិធម៌ ផ្នែកស្រាវជ្រាវសេដ្ឋកិច្ច និងទីកន្លែងធ្វើការ ធ្វើការសិក្សាស្រាវជ្រាវជារៀងរាល់ឆ្នាំ ដោយពិនិត្យមើលកត្តាសេដ្ឋកិច្ច និងសង្គម ហើយចេញជាលទ្ធផលដល់ក្រុមអាជ្ញាកណ្តាលធ្វើការពិចារណា។ ក្រុមអាជ្ញាកណ្តាល បើកសវនាការស្តាប់ការទាញហេតុផលពីសំណាក់ កម្មករនិយោជិត និយោជក និងរដ្ឋាភិបាល។ តាមធម្មតារដ្ឋាភិបាលនឹងមិនលើកឡើងអំពីតួលេខណាមួយនៅពេលភាគីផ្សេងទៀតបានលើកឡើងរួចហើយ ប៉ុន្តែ រដ្ឋាភិបាលធ្វើការទាញហេតុផលចំពោះការកំណត់ប្រាក់ឈ្នួលគោលនោះដើម្បីឲ្យស្របតាមបទដ្ឋានច្បាប់ ឬហៅថា "វង្វង់សុវត្ថិភាព" ដែលបានកំណត់ដោយច្បាប់ស្តីពីការងារយុត្តិធម៌។ ការងាររបស់ក្រុមអាជ្ញាកណ្តាលមិនមែនគ្រាន់តែបង្រួម ឬបំបាត់គម្លាតតួលេខដែលលើកឡើងដោយភាគីទាំងពីរនោះទេ ក្រុមអាជ្ញាកណ្តាលសម្រេចថា តើមានអ្វីខ្លះស្របច្បាប់ និងសមហេតុផល។ សេចក្តីសម្រេចរបស់ក្រុមអាជ្ញាកណ្តាលស្តីពី "ប្រាក់ឈ្នួលគោលថ្នាក់ជាតិ" ត្រូវបានអនុវត្តក្នុងគ្រប់វិស័យទូទាំងប្រទេសអូស្ត្រាលី។

ក្រៅពីការធ្វើបទបង្ហាញខាងលើ គណៈប្រតិភូក៏បានចូលសង្កេតដំណើរការនៃការដោះស្រាយវិវាទព្រមទាំងមើលបណ្ណាល័យ និងបរិវេណរបស់គណៈកម្មាធិការផងដែរ។

គណៈប្រតិភូមើលឃើញថា ដំណើរទស្សនកិច្ចនេះផ្តល់អត្ថប្រយោជន៍យ៉ាងច្រើន។ នៅចុងបញ្ចប់ នៃកិច្ចប្រជុំគណៈប្រតិភូបានធ្វើការស្នើសុំឲ្យមានកិច្ចសហប្រតិបត្តិការផ្លូវការឲ្យបានកាន់តែរឹងមាំថែមទៀតរវាងកម្ពុជា និងគណៈកម្មាធិការការងារយុត្តិធម៌អូស្ត្រាលីនាពេលអនាគតតាមរយៈអនុស្សារណៈនៃការយោគយល់គ្នា។ គណៈប្រតិភូកម្ពុជាបានស្នើដល់អាជ្ញាកណ្តាល ម៉ៃឃើល ហ្គេយ៍ បន្តជួយគាំទ្រផ្នែកបច្ចេកទេសក្នុងនាមជាសមាជិកគណៈកម្មការផ្តល់ប្រឹក្សាអន្តរជាតិរបស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល និងស្នើដល់គណៈកម្មាធិការការងារយុត្តិធម៌ផ្ទាល់តែម្តងចំពោះការជួយគាំទ្រដល់ការកសាងសមត្ថភាពរបស់មន្ត្រីក្រសួងការងារកម្ពុជា និងចំពោះការរីកលូតលាស់ជារួមរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

# មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបើកវគ្គបណ្តុះបណ្តាលកម្មករនិយោជិត និងតំណាងនិយោជក

ស្រី សុមេធ

មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចាប់ផ្តើមកម្មវិធីបណ្តុះបណ្តាលការទប់ស្កាត់ និងដោះស្រាយវិវាទក្នុងកន្លែងធ្វើការកាលពីថ្ងៃអង្គារ ទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤។ កម្មវិធីនេះទទួលការឧបត្ថម្ភថវិកាពីមូលនិធិលីវ៉ាយស្ត្រៅ ហើយនឹងដំណើរការរយៈពេល ២ឆ្នាំ ដោយគិតពីពេលនេះ រហូតដល់ខែកញ្ញា ឆ្នាំ២០១៦ ដោយនឹងមានសិក្ខាកាមចំនួន ៣២០ រូប អញ្ជើញមកពីរោងចក្រកាត់ដេរសំលៀកបំពាក់ចំនួន ១៦ ចូលរួម។

វគ្គបណ្តុះបណ្តាលដំបូងនេះមានកម្មករនិយោជិត និងតំណាងនិយោជកចំនួន ២០រូប មកពីក្រុមហ៊ុន ណាហ្គា ភីស ឧបតើវសិន លីមីធីត ចូលរួម ហើយអាជ្ញាកណ្តាល អាន វីរៈជាគ្រូបង្គោល។

តទៅទំព័រ ៥

## មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល...

*តមកពីទំព័រ ៤*

គិតត្រឹមចុងខែមករា ឆ្នាំ២០១៥ នេះ កម្មករនិយោជិត និងនិយោជកចំនួន ៣៣រូប អញ្ជើញមកពីរោងចក្រ ចំនួន២ ហើយ បាន ចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលនេះ។



កម្មករនិយោជិត និងតំណាងនិយោជកមកពីក្រុមហ៊ុន យូជក្រោន ចូលរួមវគ្គបណ្តុះបណ្តាលទី១ ក្នុងចំណោមវគ្គចំនួនពីរផ្សេងទៀត

កម្មវិធីនេះត្រូវបានរៀបចំឡើងដោយ មានការយល់ដឹងថា វិវាទការងារប៉ះពាល់ ដល់ផលិតភាព និងផលិតកម្ម ដូច្នេះត្រូវធ្វើ ការដោះស្រាយឲ្យបានឆាប់។ ដូច្នេះហើយ កម្មវិធីនេះផ្តោតលើការផ្តល់អំណាចដល់ កម្មករនិយោជិត ថ្នាក់ដឹកនាំ សហជីព អ្នក គ្រប់គ្រងផ្នែកធនធានមនុស្ស ឬប្រធានផ្នែក ប្រតិភូបុគ្គលិក និងតំណាងនិយោជក តាម រយៈជំនាញចាំបាច់សម្រាប់ការបង្កើត និង រក្សាទំនាក់ទំនងការងារដោយលើកទឹកចិត្ត ឲ្យមានការប្រាស្រ័យទាក់ទងដើម្បីទប់ស្កាត់ និងដោះស្រាយវិវាទការងារនៅនឹងរោងចក្រ តែម្តង។

មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបាន រៀបចំកម្មវិធីរៀនសូត្រសម្រាប់មនុស្សពេញ វ័យដោយក្នុងនោះមានការបណ្តុះបណ្តាល ដោយប្រើករណីសិក្សាជាក់ស្តែង និងលំហាត់ អនុវត្ត ដើម្បីកសាងសមត្ថភាពរបស់សិក្ខា កាមលើប្រធានបទបីដូចជា ការកសាងទំនាក់ ទំនងនៅកន្លែងធ្វើការ យន្តការសហប្រតិបត្តិ ការនៅកន្លែងធ្វើការ និងជំនាញចរចា។ វគ្គ បណ្តុះបណ្តាលនេះមានអាជ្ញាកណ្តាល និង មន្ត្រីជាន់ខ្ពស់របស់មូលនិធិក្រុមប្រឹក្សាអាជ្ញា កណ្តាល ដែលមានជំនាញផ្នែកទំនាក់ទំនង វិជ្ជាជីវៈនៅកម្ពុជា ជាគ្រូបង្គោល។

មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលមាន បទពិសោធន៍យ៉ាងទូលំទូលាយក្នុងការបណ្តុះ បណ្តាល កម្មករនិយោជិត សហជីព និយោជក សមាគមនិយោជក មន្ត្រីរដ្ឋាភិបាល ថៅក្រុម មេធាវី តំណាងសង្គមស៊ីវិល និងភាគីពាក់ព័ន្ធ ដទៃទៀតក្នុងវិស័យទំនាក់ទំនងវិជ្ជាជីវៈ។

# សិទ្ធិចាត់ចែង-គ្រប់គ្រងនឹងសុខភាព-សុវត្ថិភាពរបស់កម្មករនិយោជិត

ចូសេផ ចេមស៍ អ៊ែលឌឺរ៍

ដើម្បីយល់ដឹងកាន់តែច្បាស់ថា តើ ច្បាប់ថ្លឹងថ្លែងសិទ្ធិចាត់ចែង-គ្រប់គ្រងនឹង សុខភាព-សុវត្ថិភាពរបស់កម្មករនិយោជិត យ៉ាងដូចម្តេច ហេតុផលនៃសេចក្តីសម្រេច របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងចំណុច វិវាទទី ៥ នៃសំណុំរឿង លេខ ១១០/១៤ - យេផេន វ៉ាក់ អេស.អ៊ី.អេ(ភ្នំពេញ)ខូអិលធីឌី ត្រូវបានលើកយកមកពិភាក្សាក្នុងអត្ថបទ នេះ។ សហព័ន្ធសហជីពអំណាចកម្មករខ្មែរ (KWPFU) ជាដើមបណ្តឹងចំពោះក្រុមហ៊ុន យេផេន វ៉ាក់ អេស.អ៊ី.អេ(ភ្នំពេញ)ខូអិលធីឌី (ភាគីនិយោជក) ក្នុងសំណុំរឿងដែលចុះ បញ្ជីនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ភាគី និយោជកជាក្រុមហ៊ុនដែលមានអាជីវកម្ម ចម្បង ក្នុងការកាត់ដេរសំលៀកបំពាក់ ហើយ បច្ចុប្បន្ននេះក្រុមហ៊ុននេះមានកម្មករនិយោជិត ប្រមាណ ៥៣៥ នាក់កំពុងបម្រើការងារ។ សហព័ន្ធសហជីពអំណាចកម្មករខ្មែរទទួល បានការផ្ទេរសិទ្ធិពីកម្មករនិយោជិតក្នុងក្រុម ហ៊ុនចំនួន ១៧៧នាក់ ឲ្យតំណាងខ្លួនរហូត ដល់ចប់នីតិវិធីនៃការដោះស្រាយវិវាទនេះ។

ក្នុងសំណុំរឿងនេះ សហព័ន្ធសហជីព អំណាចកម្មករខ្មែរបានជំទាស់ទៅនឹងបទ បញ្ជាផ្ទៃក្នុងក្រុមហ៊ុនដែលតម្រូវឲ្យកម្មករ និយោជិតបង្ហាញកាតអនុញ្ញាត និងស្នេ មេដៃទើបអាចប្រើបន្ទប់ទឹកបាន។ ភាគី និយោជកផ្តល់កាតអនុញ្ញាតប្រើបន្ទប់ទឹក នេះមួយសន្លឹកដល់កម្មករនិយោជិតមួយក្រុម ដែលមានសមាជិកចំនួន ២៥នាក់ ដែល ជាហេតុធ្វើឲ្យកម្មករនិយោជិតដែលត្រូវការ ប្រើបន្ទប់ទឹកត្រូវរង់ចាំយូរ។ ភាគីកម្មករ និយោជិតទាមទារឲ្យភាគីនិយោជកបញ្ឈប់ ការអនុវត្តបែបនេះទាំងស្រុង ឬជម្រើស មួយទៀតនោះ ភាគីនិយោជកត្រូវផ្តល់កាត អនុញ្ញាតបន្ថែមដើម្បីកាត់បន្ថយពេលវេលា រង់ចាំប្រើបន្ទប់ទឹក។ ភាគីនិយោជកបាន អះអាងថា ការធ្វើបែបនេះគឺដើម្បីប្រមូល ទិន្នន័យថា តើកម្មករចូលបន្ទប់ទឹកប៉ុន្មាន ដងក្នុងមួយថ្ងៃ និងតើការប្រើប្រាស់បន្ទប់ទឹក នេះចាប់ផ្តើមប៉ះពាល់ដល់ផលិតភាពដល់ កម្រិតណា?

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការ ពិនិត្យមើលលើភាពស្របច្បាប់នៃការអនុវត្ត របស់ភាគីនិយោជក។ ក្រុមប្រឹក្សាអាជ្ញា

*តទៅទំព័រ ៦*

## សិទ្ធិចាត់ចែង-គ្រប់គ្រងនឹង...

*តមកពីទំព័រ ៦*




កណ្តាលបានពិចារណាអំពីសិទ្ធិចាត់ចែង និងគ្រប់គ្រងក្នុងមាត្រា២ នៃច្បាប់ស្តីពីការងារ (១៩៩៧) ដែលចែងថា "...សហគ្រាសនីមួយៗអាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗនោះមានប្រើមនុស្សមួយក្រុមធ្វើការរួមគ្នាក្នុងទីកន្លែងណាមួយជាប្រាកដ ដូចជារោងចក្រ រោងជាង ការដ្ឋាន ។ល។ ក្រោមការគ្រប់គ្រង និង ដឹកនាំនៃនិយោជក..." ។ ប៉ុន្តែច្បាប់ការងារមិនបានកំណត់លម្អិតថាតើសិទ្ធិនៃការចាត់ចែងកម្រិតណាដែលសមស្របឡើយ។ នៅក្នុងសេចក្តីបង្គាប់មុនៗ (០៦២/០៦, ១០៨/០៦, ០៣៣/០៧, ១១៩/០៩) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រា២ ថា និយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ដរាបណាសិទ្ធិនេះបានធ្វើឡើងដោយស្របច្បាប់ និងមានលក្ខណៈសមរម្យ។ ជាងនេះទៅទៀតការពិនិត្យថា តើអ្វីសមរម្យ ឬមិនសមរម្យត្រូវបានកំណត់តាមអង្គហេតុនៃសណ្តុំរឿងនីមួយៗ។

ដើម្បីរក្សាសង្គតិភាព និងតម្លាភាព ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ស្របតាមសេចក្តីបង្គាប់មុនៗស្តីពីចំណុចវិវាទនេះ។ សេចក្តីបង្គាប់ ២៧៥/១៣ - កាឡាខេម អ៊ិនវេសមេន ចែងថា និយោជកមានសិទ្ធិចាត់វិធានការដាក់វិន័យលើកម្មករនិយោជិតដែលគេចវេសពីការងារតាមច្បាប់ស្តីពីការងារ និងបទបញ្ជាផ្ទៃក្នុង។ ប៉ុន្តែបើវិធានការទាំងនោះប៉ះពាល់ដល់សុខភាព និងសុវត្ថិភាពរបស់កម្មករនិយោជិត វិធានការទាំងនោះមិនសមរម្យឡើយ។ យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចជាឯកច្ឆ័នថា ការរំលោភសិទ្ធិប្រើប្រាស់បន្ទប់ទឹក និងពេលវេលារង់ចាំយូរដើម្បីប្រើបន្ទប់ទឹក ប៉ះពាល់ដល់សុខភាព និងសុវត្ថិភាពរបស់កម្មករនិយោជិតដែលមិនទទួលបានការអនុញ្ញាតឲ្យសម្រាកដើម្បីចូលបន្ទប់ទឹក។ ដូច្នេះ ការអនុវត្តរបស់ភាគីនិយោជកមានលក្ខណៈមិនសមរម្យ ហើយខុសច្បាប់។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឲ្យភាគីនិយោជកបញ្ឈប់ការអនុវត្តដែលតម្រូវឲ្យកម្មករនិយោជិតប្រើប្រាស់កាត និងស្កេនមេដៃមុនពេលចូលបន្ទប់ទឹក។

ទោះបីជាសេចក្តីសម្រេចនេះមិនមែនជាសេចក្តីសម្រេចថ្មី ឬមានភាពចម្រូងចម្រាស សេចក្តីសម្រេចនេះបានបញ្ជាក់ឡើងវិញអំពីសារៈសំខាន់នៃការធ្វើឲ្យមានតុល្យភាពរវាងវិធានការដើម្បីផលិតភាពនឹងសុខភាពរបស់កម្មករនិយោជិត។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលគោរពសិទ្ធិចាត់ចែង និងគ្រប់គ្រងរបស់និយោជក និងការរក្សា និងតាមដានផលិតភាព ប៉ុន្តែសេចក្តីសម្រេចនេះបង្ហាញថា មិនត្រូវមានការរំលោភលើសុខភាព និងសុវត្ថិភាពរបស់កម្មករនិយោជិតដើម្បីផលិតភាពឡើយ។

## អាជ្ញាកណ្តាល សុខ ម៉ាធឿង៖ ខ្ញុំចង់ឃើញកម្ពុជាដូចប្រទេសជឿនលឿនដទៃ

ស្រី សុមេធ

"លោកគ្រូ" ជាពាក្យដែលអាជ្ញាកណ្តាល និងបុគ្គលិកក្នុងការិយាល័យក្រុមប្រឹក្សាអាជ្ញាកណ្តាលស្ទើរគ្រប់គ្នាហៅ បណ្ឌិត សុខ ម៉ាធឿង ការហៅបែបនេះមិនមានន័យថា គ្រប់គ្នាជាសិស្ស ឬអតីតសិស្សរបស់លោកឡើយ តែជាការបង្ហាញអំពីការគោរពចំពោះលោក ដោយសារលោកជារៀមច្បងដែលបានបម្រើការងារក្នុងស្ថាប័ននេះអស់រយៈពេលជាច្រើនឆ្នាំ និងជាអតីតប្រធានក្រុមប្រឹក្សាភិបាលមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលដំបូងគេបំផុតនៅពេលមូលនិធិនេះត្រូវបានបង្កើតឡើង នៅឆ្នាំ ២០០៤។

អាជ្ញាកណ្តាល ម៉ាធឿង ជាបញ្ញវន្តខ្មែរមួយរូបដែលមានការតាំងចិត្តខ្ពស់ក្នុងការចូលរួមចំណែកក្នុងវិស័យសេដ្ឋកិច្ច និងច្បាប់របស់កម្ពុជាក្នុងពេលដែលកម្ពុជាមានការផ្លាស់ប្តូររបបនយោបាយ និងស្ថានភាពពីសន្តិភាពទៅចលាចល និងវិលត្រលប់ពីចលាចលមកសន្តិភាពវិញ។

ប្រសូត្រនៅឆ្នាំ ១៩៣៨ ក្នុងខេត្តកណ្តាល អាជ្ញាកណ្តាល ម៉ាធឿង បានតស៊ូខិតខំប្រឹងប្រែងរៀនសូត្ររហូតដល់ចប់សាលាកសិកម្មជាតិនៅឆ្នាំ១៩៦២។ ក្រោយមក ទន្ទឹមពេលដែលលោកកំពុងបម្រើការងារក្នុងនាយកដ្ឋានជលផលរបស់ក្រសួងកសិកម្ម លោកក៏បានទទួលបរិញ្ញាបត្រសេដ្ឋកិច្ចពីមហាវិទ្យាល័យសេដ្ឋកិច្ច និងច្បាប់នៅឆ្នាំ១៩៦៩។ ភ្លាមៗបន្ទាប់ពីទទួលបានបរិញ្ញាបត្រនេះ លោកទទួលបានអាហាររូបករណ៍ទស្សនកិច្ចសិក្សាអំពីរុក្ខាប្រមាញ់រយៈពេលមួយឆ្នាំនៅប្រទេសបារាំង។ ពេលទៅដល់ទីនោះ លោកបានចាប់យកឱកាសបន្តការសិក្សាយកបរិញ្ញាបត្រភាសាបារាំងនៅសាកលវិទ្យាល័យប៉ារីស I។ ទោះបីជាបានបរិញ្ញាបត្រនេះហើយក្តី លោកនៅតែមានបំណងប្រាថ្នាចាប់យកបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ចថែមទៀតនៅពេលលោកឃើញការប្រកាសប្រលងជ្រើសរើសនិស្សិតឲ្យចូលសិក្សា ហើយលោកក៏បានចុះឈ្មោះចូលប្រលង តែបំណងប្រាថ្នានេះមិនបានសម្រេចឡើយដោយសារក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ រដ្ឋាភិបាលថ្មីបានហៅមន្ត្រីរាជការដែលកំពុងសិក្សានៅក្រៅប្រទេសទាំងអស់ត្រលប់ចូលមកកម្ពុជាវិញ។

ក្នុងពេលស្ថានភាពនយោបាយកំពុងចលាចលក្រោយរដ្ឋប្រហារ លោក ម៉ាធឿង បានខិតខំប្រឹងប្រែងសាជាថ្មីទៀតស្នើសុំ

*តទៅទំព័រ ៧*

## អាជ្ញាកណ្តាល សុខ ម៉ាធឿង៖ ខ្ញុំចង់...

*តមកទៅទំព័រ ៦*

អាហាររូបករណ៍ទៅសិក្សានៅប្រទេសបារាំង ហើយម្តងនេះលោកសម្រេចបានដូចបំណងមែន គឺលោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបន្ទាប់មកបញ្ចប់ថ្នាក់បណ្ឌិតផ្នែកសេដ្ឋកិច្ច ដោយជាប់ចំណាត់ថ្នាក់លេខ២ ពីសាកលវិទ្យាល័យប៉ារីស I នៅឆ្នាំ១៩៧៦។

ក្រឡេកមើលមកស្ថានភាពនយោបាយនៅកម្ពុជាវិញ ក្រោយឡើងកាន់អំណាចរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ(ខ្មែរក្រហម) បានធ្វើការឃោសនាអូសទាញបញ្ញវន្តខ្មែរនៅបរទេសឲ្យត្រលប់ចូលមកកម្ពុជាវិញ ដើម្បីជួយធ្វើការរៀបចំ និងអភិវឌ្ឍប្រទេស។ នៅពេលបានឮដំណឹងនេះ ហើយស្របនឹងការតាំងចិត្តរបស់លោក ដែលប៉ុនប៉ងយកចំណេះដឹងពីការសិក្សានៅបរ-ទេសមកបម្រើមាតុភូមិរបស់ខ្លួនតាមរយៈការងារសាធារណៈនោះ លោក ម៉ាធឿង បានសម្រេចចិត្តត្រលប់ចូលមកកម្ពុជាវិញ។

ចុងឆ្នាំ ១៩៧៦ ពេលមកដល់កម្ពុជា លោកមានការភ្ញាក់ផ្អើល និងតក់ស្លុតដែលឃើញទីក្រុងភ្នំពេញស្ងាត់ជ្រងំគ្មានមនុស្សរស់នៅ ហើយលោកត្រូវបានពួកខ្មែរក្រហមដឹកយកទៅដាក់នៅបឹងត្របែក និងហាមចេញពីបរិវេណសាលាបឋមសិក្សាបឹងត្របែក។ នៅដើមឆ្នាំ១៩៧៧ ពោលគឺ ៣ខែក្រោយការឃុំឃាំងនៅបឹងត្របែក លោកត្រូវបានពួកខ្មែរក្រហមបញ្ជូនទៅធ្វើការងារសហករនៅស្រុកស្ទឹងត្រង់ ក្នុងខេត្តកំពង់ចាម។

ក្រោយរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ ១៩៨១ ដោយមើលឃើញថា កម្ពុជាមិនទាន់មានស្ថិរភាពនៅឡើយ គណៈកម្មការជាន់ខ្ពស់ទទួលបន្ទុកជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិ បានជួយជ្រោមជ្រែងលោកឲ្យត្រលប់ទៅប្រទេសបារាំងវិញដើម្បីសុវត្ថិ-ភាព។

នៅប្រទេសបារាំង លោកបានបម្រើការងារជាអ្នកពិគ្រោះយោបល់របស់រដ្ឋា-ភិបាលបារាំង ជាសាស្ត្រាចារ្យនៅសាកល-វិទ្យាល័យប៉ារីស I II និងVIII។ លោកក៏ត្រូវបានរដ្ឋាភិបាលបារាំងបញ្ជូនទៅធ្វើជាអ្នកពិគ្រោះយោបល់សេដ្ឋកិច្ចនៅទ្វីបអាហ្វ្រិក ពីឆ្នាំ ១៩៨៤ រហូតដល់ឆ្នាំ១៩៩២។

ទោះបីលោកធ្វើការងារនៅឆ្ងាយពីកម្ពុជាក៏ពិតមែន លោកនៅតែតាមដានមើលសភាពការណ៍នយោបាយកម្ពុជាដើម្បីរកឱកាសវិលត្រលប់មកមាតុភូមិវិញ។ ដោយមើលឃើញអំពីដំណើរការនៃកិច្ចចរចាសន្តិភាពនៅទីក្រុងប៉ារីស និងដោយមានការឈឺចាប់ចំពោះការមើលឃើញការស្លាប់ និងការប្រយុទ្ធហែកហួរគ្នារវាងខ្មែរ និងខ្មែរ នៅខែកក្កដា ឆ្នាំ១៩៩២ លោកបានទាក់ទងជាមួយនឹងគណៈកម្មការជាន់ខ្ពស់ទទួលបន្ទុកជនភៀសខ្លួនដើម្បីវិលមកកម្ពុជាវិញ ហើយលោកបានបម្រើការងារជាអ្នកបកប្រែរយៈពេល ៦ខែ ស្របតាមតម្រូវការរបស់ស្ថាប័ននេះដោយសារ លោកចេះនិយាយភាសាបារាំងបានយ៉ាងស្ទាត់ជំនាញ។

នៅឆ្នាំ១៩៩៣ ជាការចូលរួមចំណែកក្នុងការស្វែងរក និងរក្សាសន្តិភាពកម្ពុជាជាលើកដំបូង លោកបានបំពេញតួនាទីជាមន្ត្រីអន្តរជាតិប្រចាំស្ថានីយ៍បោះឆ្នោតនៅព្រៃកតាមាក់។

ក្នុងដំណើរវិលត្រលប់របស់លោកចូលមកកម្ពុជាលើកចុងក្រោយនេះ លោក ម៉ាធឿង បានបម្រើការងារជាអ្នកពិគ្រោះយោបល់របស់អង្គការអន្តរជាតិធំៗដូចជា ធនាគារអភិវឌ្ឍអាស៊ី ធនាគារពិភពលោក ជាសាស្ត្រា-ចារ្យជាន់ខ្ពស់ នៅតាមបណ្តាសាកលវិទ្យាល័យនានា រួមទាំង សាលាភូមិន្ទរដ្ឋបាល ក្រសួងសាធារណៈការ និងដឹកជញ្ជូន និងមជ្ឈ-មណ្ឌលបណ្តុះបណ្តាល មេធាវី ដោយបានចែករំលែកទាំងចំណេះដឹង និងបទពិសោធន៍របស់លោកក្នុងនាមជាសមាជិកនៅក្នុងស្ថាប័នល្បីៗរបស់ប្រទេសបារាំងដូចជាសមាគមហិរញ្ញវត្ថុ មជ្ឈមណ្ឌលសន្ទានកម្ម និងមជ្ឈត្តការ ព្រមទាំងសមាគមអភិវឌ្ឍថ្មី។

ដោយសារតែចំណេះដឹង និងបទពិ-សោធន៍ទាំងអស់នេះ លោក ម៉ាធឿង ត្រូវបានជ្រើសរើសជាអាជ្ញាកណ្តាល ដោយក្រសួងទទួលបន្ទុកការងារក្រោមកិច្ចសហការជាមួយអង្គការពលកម្មអន្តរជាតិ នៅពេលក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅកម្ពុជាឆ្នាំ ២០០៣។

លោកបានលើកឡើងអំពីការចូលរួមនៅក្នុងការងារនេះថា “តាំងពីយូរមកហើយ ខ្ញុំចង់ឃើញកម្ពុជាមានមធ្យោបាយដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ជឿនលឿន ដូចប្រទេសដទៃទៀតដែរ”។

លោកបន្ថែមថា លោកបានមើលឃើញប្រទេសជឿនលឿនទាំងនោះប្រើប្រាស់មធ្យោបាយដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រកបដោយប្រសិទ្ធភាព ដូច្នេះហើយ លោកចង់នាំយកបទពិសោធន៍របស់លោកក្នុងនាមជាសមាជិកមជ្ឈមណ្ឌលសន្ទានកម្ម និងមជ្ឈត្តការបារាំង មកចូលរួមចំណែកក្នុងការងារនេះនៅប្រទេសកម្ពុជា។

ថ្លែងអំពីការងារបច្ចុប្បន្នរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លោក ម៉ាធឿង មានប្រសាសន៍ ដោយមិនស្ទាក់ស្ទើរថា “ខ្ញុំមានមោទនភាពដែលបានធ្វើជាអាជ្ញាកណ្តាលក្នុងក្រុមប្រឹក្សាអាជ្ញាកណ្តាល ព្រោះនេះជាស្ថាប័នដែលមានតម្លាភាព និងគ្មានអំពើពុករលួយ”។

“ខ្ញុំមានមោទនភាពដែលបានធ្វើជាអាជ្ញាកណ្តាលក្នុងក្រុមប្រឹក្សាអាជ្ញាកណ្តាល ព្រោះនេះជាស្ថាប័នដែលមានតម្លាភាព និងគ្មានអំពើពុករលួយ។”

អាជ្ញាកណ្តាល សុខ ម៉ាធឿង



## ទំព័របុគ្គលិក



កញ្ញា មីឈែល ហ៊ាង បញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ យេល ដោយទទួលបានបរិញ្ញាបត្រវិទ្យាសាស្ត្រទំនាក់ទំនង វិជ្ជាជីវៈ និងការងារ ព្រមទាំងជំនាញបន្ថែមផ្នែកសេដ្ឋកិច្ច ច្បាប់ និងសង្គម។ ឆ្នាំនេះ កញ្ញានឹងធ្វើការក្នុងផ្នែកបណ្តុះបណ្តាល និងទំនាក់ទំនងនៃមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងនាមជាបញ្ញវន្ត កម្មវិធីលុស្ស (Luce Scholar) ឆ្នាំ ២០១៤ ដល់ ២០១៥។ កញ្ញាធ្លាប់បានចុះកម្មសិក្សាជាមួយអង្គការបណ្តាញស្ត្រីកសាងសន្តិភាពសាកល ការិយាល័យអនុវត្តច្បាប់នៃគណៈកម្មការសិទ្ធិមនុស្ស ទីក្រុងញូយ៉ក និងផ្នែកការងារ និងច្បាប់ការងារនៅការិយាល័យច្បាប់ Proskauer Rose LLP។



លោក ម៉ុន សាម៉ឺឌី បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកច្បាប់ពីសាកលវិទ្យាល័យកម្ពុជា និងថ្នាក់បរិញ្ញាបត្រផ្នែកភាសាអង់គ្លេសសម្រាប់ការទំនាក់ទំនងពីសាកលវិទ្យាល័យពុទ្ធិសាស្ត្រ។ លោកធ្លាប់ធ្វើជា ឯកអគ្គរាជទូតផ្នែកយុត្តិធម៌ សម្រាប់កម្មវិធីបណ្តុះបណ្តាលលើវិស័យយុត្តិធម៌ នៅអង្គការគោលដៅយុត្តិធម៌ក្នុងរាជធានីភ្នំពេញ និងធ្លាប់ជាមន្ត្រីទំនាក់ទំនងនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការបេតិកភ័ណ្ឌពិភពលោក លើកទី៣៧ ដែលត្រូវបានរៀបចំដោយអង្គការយូណេស្កូ និងគណៈកម្មការជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយមានការគាំទ្រពីគណៈប្រធាននៃទីស្តីការគណរដ្ឋមន្ត្រី។ សព្វថ្ងៃលោកជា មន្ត្រីអប់រំច្បាប់ និងបកប្រែនៅមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល។



កញ្ញា ប៊ុន ប៊ូរ៉ានី ជាមន្ត្រីច្បាប់ បានបញ្ចប់ការសិក្សាបរិញ្ញាបត្រផ្នែកច្បាប់ ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា តាមរយៈអាហាររូបករណ៍សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។ កញ្ញាបានជាប់ជានិស្សិតឆ្នើមមួយរូបក្នុងចំណោមនិស្សិតឆ្នើមទាំង ១០រូប នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ ក្នុងឆ្នាំ២០១១។ ដោយសារមានគោលបំណងក្នុងការចូលរួមអភិវឌ្ឍសង្គម កញ្ញាធ្លាប់បម្រើការងារជាអ្នកឃ្លាំមើលសាលាក្តីខ្មែរក្រហមនៃគម្រោងផ្តួចផ្តើមយុត្តិធម៌ប្រចាំតំបន់អាស៊ី ជាជំនួយការគម្រោងទទួលបានយុត្តិធម៌នៅកម្ពុជា និងជាជំនួយការរដ្ឋបាលនៃគ្លីនិកច្បាប់ នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។ ក្រៅពីនេះ កញ្ញាធ្លាប់ចូលរួមសកម្មភាពលើកស្ទួយសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា និងផ្សព្វផ្សាយពីសិទ្ធិស្ត្រី និងកុមារី ជាមួយអង្គការសហប្រជាជាតិសម្រាប់ស្ត្រី (UN Women)។



លោក ចូសេផ ចេមស៍ អ៊ែលដឺរ៍ ជានិស្សិតផ្នែកច្បាប់នៅសាកលវិទ្យាល័យម៉ាកឃ្វៃរី ស្ថិតក្នុងទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី។ លោកនឹងចូលបម្រើការងាររយៈពេល ៣ខែ ក្នុងនាមជាអ្នកហ្វឹកហាត់ផ្នែកច្បាប់នៅមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលក្រោមកម្មវិធីដកពិសោធន៍ការងាររបស់សាកលវិទ្យាល័យនេះ។ លោក ចូសេផ បានបញ្ចប់បរិញ្ញាបត្រធុរកិច្ចអន្តរជាតិ ហើយលោកនឹងបញ្ចប់ថ្នាក់វិជ្ជាជីវៈមេធាវីនៅចុងឆ្នាំ ២០១៥។ ទោះបីជាលោកនៅមានវ័យក្មេងនៅឡើយក្តី លោក ចូសេផ បានចូលប្រឡូកក្នុងបរិយាកាសអន្តរជាតិដ៏មមាញឹកនៃវិស័យច្បាប់ ហើយលោកក៏ជាមនុស្សដែលស្រលាញ់ចូលចិត្តយុត្តិធម៌សង្គម និងការអភិវឌ្ឍវិស័យទំនាក់ទំនងវិជ្ជាជីវៈផងដែរ។ ទន្ទឹមនឹងការបម្រើការងារនៅមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល លោក ចូសេផ ក៏ជាគ្រូបង្វឹកតស៊ូមតិផ្នែកច្បាប់នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។


ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨១ ៨១៤ និង +៨៥៥ ២៣ ៨៨១ ៩១៨
អ៊ីម៉ែល៖ info@arbitrationcouncil.org & Website: www.arbitrationcouncil.org



អ្នកចូលរួមចែករំលែកក្នុងការបោះពុម្ពផ្សាយនេះ
អ្នកសរសេរអត្ថបទ៖ លោក ហ៊ុន ចិន្តា លោកស្រី ជុំ ចរិយា លោក ចូសេផ ចេមស៍ អ៊ែលដឺរ៍ លោក ស្រី សុមេធ
ក្រុមពិនិត្យ និងកែសម្រួល៖ លោក ហានស៍ ហ្វង កញ្ញា ហៃឌី ហ៊ុលសណិកឆ៍ លោកស្រី អាន វីរៈ
កញ្ញា មីឆែល ហ៊ាង លោក ចូសេផ ចេមស៍ អ៊ែលដឺរ៍
អ្នកបកប្រែ៖ លោក ស្រី សុមេធ និងលោក ម៉ុន សាម៉ឺឌី